CITY OF LONG BEACH **PRESS RELEASE**

**សេចក្តីប្រកាសព័ត៌មាន**

ថ្ងៃទី ២ ខែមិថុនាឆ្នាំ ២០២០
ទំនាក់ទំនង៖ មជ្ឈមណ្ឌលព័ត៌មានរួមនៃទីក្រុងឡុងប៊ិច 562.570.NEWS(6397) jic@longbeach.gov

សម្រាប់សេចក្តីប្រកាសជាបន្ទាន់

# ទីតាំងធ្វើតេស្ត COVID-19 ដែលគ្រប់គ្រងដោយទីក្រុងឡុងប៊ិចនឹងបន្តប្រតិបត្តិការឡើងវិញ

*ប្រកាសអំពីសេវាកម្មធ្វើតេស្តចល័តថ្មីផងដែរ*

ទីក្រុងឡុងប៊ិច, រដ្ឋកាលីហ្វ័រញ៉ា - បន្ទាប់ពីការបិទទីតាំងធ្វើតេស្ត COVID-19 នៅថ្ងៃទី ១ និងថ្ងៃទី ២ ខែមិថុនាដើម្បីធានាសុវត្ថិភាពដល់សាធារណជននិងអ្នកជំនាញផ្នែកវេជ្ជសាស្ត្រនោះទីតាំងធ្វើតេស្តដែលគ្រប់គ្រងដោយទីក្រុងភាគច្រើននឹងបើកដំណើរការឡើងវិញនៅថ្ងៃស្អែកទី ៣ ខែមិថុនា។

ទីក្រុងឡុងប៊ិចក៏កំពុងពង្រីកលទ្ធភាពទទួលបានការធ្វើតេស្ត៍ COVID-19 ជាមួយនឹងសេវាកម្មចល័តថ្មីសម្រាប់ប្រជាជនដែលមិនអាចធ្វើដំណើរបានរួមទាំងបុគ្គលនៅឯលំនៅដ្ឋានផ្ទាល់ខ្លួននិងអ្នកដែលរស់នៅមណ្ឌលថែទាំមនុស្សវ័យចំណាស់កន្លែងថែទាំរយៈពេលវែងនិងផ្ទះស្តារនីតិសម្បទា។

លោកអភិបាលក្រុង Robert Garcia បានមានប្រសាសន៍ថា "យើងនៅតែមានវិបត្តិសុខភាពនៅឡុងប៊ិចហើយវាជាការសំខាន់ណាស់ដែលយើងត្រូវបន្តធ្វើតេស្តដល់ប្រជាជន។"

កន្លែងធ្វើតេស្តដែលនឹងបើកឡើងវិញដោយមានម៉ោងកែប្រែនៅថ្ងៃទី ៣ ខែមិថុនារួមមាន៖

- មហាវិទ្យាល័យនៃទីក្រុងឡុងប៊ិច, សាខាឆ្នេរសមុទ្រប៉ាស៊ីហ្វិក (1305 E. Pacific Coast Hwy.) ចាប់ពីម៉ោង ១០ ព្រឹកដល់ម៉ោង ១ រសៀល
- សាលារៀន Cabrillo High School (2001 Santa Fe Ave.) ចាប់ពីម៉ោង ១០ ព្រឹកដល់ម៉ោង ១ រសៀល
- សាលារៀន Jordan High School (6500 Atlantic Ave.) ចាប់ពីម៉ោង ៣ រសៀលដល់ម៉ោង ៥ ល្ងាច

សាលារៀន Jordan Plus (171 W. Bort St.) និងមន្ទីរពេទ្យ St. Mary (1050 Linden St.) មិនបានបិទហើយនៅតែបើកចំហរ។ ការណាត់ជួបសម្រាប់ករណីថ្មីគឺតំរូវសម្រាប់គ្រប់កន្លែងធ្វើតេស្តទាំងអស់។ ការណាត់ជួបអាចកំណត់តាមអ៊ិនធរណេតបានឬដោយទូរស័ព្ទមកលេខ 562.570.INFO (4636)។

ការធ្វើតេស្តនៅឯស្តាត Veterans Memorial នៅតែបិទរហូតដល់មានការជូនដំណឹងបន្ថែម។

គ្លីនិកធ្វើរោគវិនិច្ឆ័យរហ័ស (RAC) ដែលមានទីតាំងនៅមហាវិទ្យាល័យនៃទីក្រុងឡុងប៊ិច, សាខាឆ្នេរសមុទ្រប៉ាស៊ីហ្វិកក៏នឹងបើកដំណើរការវិញនៅថ្ងៃទី ៣ ខែមិថុនាផងដែរចាប់ពីម៉ោង ១០ ព្រឹកដល់ម៉ោង ២ រសៀល។

សេវាកម្មធ្វើតេស្តចល័តថ្មីដែលឥតគិតថ្លៃនេះត្រូវបានបម្រុងទុកសម្រាប់អ្នកដែលមិនអាចចេញពីផ្ទះបានដោយសារតែបញ្ហាទាក់ទងនឹងការធ្វើដំណើរនិងការដឹកជញ្ជូន។ អង្គភាពចល័តនេះក៏នឹងផ្តល់អត្ថប្រយោជន៍ដល់អ្នកដែលរស់នៅក្នុងសហគមន៍រួម កន្លែងរស់នៅដែលខ្វះបុគ្គលិកនៅនឹងកន្លែងដើម្បីគ្រប់គ្រងការធ្វើតេស្ត ឬកន្លែងដែលមិនអាចធ្វើតេស្តដោយឯករាជ្យបាន។ ការធ្វើតេស្តដែលអនុវត្តដោយការប្រើសំឡីគឺមានសម្រាប់អ្នកផ្តល់ការថែទាំដល់បុគ្គលដែលមិនអាចចេញពីផ្ទះបាន។ អ្នកដែលមានចំណាប់អារម្មណ៍ចង់ស្នើសុំការធ្វើតេស្តចល័តអាចដាក់សំណុំបែបបទតាមគេហទំព័រ COVID-19 របស់ទីក្រុងឬទូរស័ព្ទមកលេខ (562) 570-INFO (4636)។

សេវាកម្មធ្វើតេស្តចល័តត្រូវបានផ្តល់ជូនដោយក្រុមប្រមូលដឹកជញ្ជូននិងវិភាគ (Collection Transportation and Analysis Team) ដែលជាក្រុមជំនាញដែលរួមមានគ្រូពេទ្យនិងឆ្មាំជាតិ។ ការបញ្ជូនឆ្មាំជាតិគឺជាកិច្ចប្រឹងប្រែងផ្នែកមនុស្សធម៌តែប៉ុណ្ណោះហើយមានគោលបំណងលើកកម្ពស់សុខ

ភាពសាធារណៈនិងសេវាកម្មទីក្រុងដោយផ្តល់ការគាំទ្រផ្នែកបុគ្គលិកបន្ថែម។ ឆ្មាំជាតិត្រូវបានបញ្ជូនមកឡុងប៊ិចដំបូងកាលពីខែមេសាដើម្បីបំពេញមុខងារគាំទ្រផ្នែកមនុស្សធម៌ខាងដឹកនាំសាស្ត្រនិងរដ្ឋបាល។ មុខងារមុនៗរបស់ឆ្មាំជាតិរួមមានការជួយបុគ្គលិកពេទ្យគ្រប់គ្រងចរាចរណ៍ចូលនិងចេញនៅជុំវិញគ្លីនិកធ្វើរោគវិនិច្ឆ័យរហ័ស (RAC) នៃទីក្រុងនិងជួយក្នុងការសម្អាតផ្ទះនិងសេវាកម្មអាហារនៅជម្រកបណ្តោះអាសន្ន។

រហូតមកដល់ពេលនេះឡុងប៊ិចបានអនុវត្តតេស្ត COVID-19 ជាង 39,000 តេស្តតាមរយៈទីតាំងចំនួន ៤ ដែលគ្រប់គ្រងដោយទីក្រុងគឺមន្ទីរពេទ្យសេនម៉ារី ទីតាំងដែលគ្រប់គ្រងដោយរដ្ឋនៅសាលារៀន Jordan Plus High School និងកន្លែងពិសោធន៍ឯកជន។ បន្ថែមពីលើជម្រើសធ្វើតេស្តសាធារណៈទាំងនេះបុគ្គលម្នាក់ៗអាចទទួលបានការធ្វើតេស្ត COVID-19 តាមរយៈគ្រូពេទ្យរបស់ពួកគាត់។

សម្រាប់ព័ត៌មានថ្មីៗអំពីជំងឺកូវីដ-១៩រួមទាំងព័ត៌មានលម្អិតអំពីអ្វីដែលទីក្រុងឡុងប៊ិចកំពុងអនុវត្តដើម្បីការពារសុវត្ថិភាពដល់ប្រជាជនសូមមេត្តាចូលទៅកាន់គេហទំព័រ longbeach.gov/COVID19 ហើយតាមដាន @LongBeachCity នៅលើបណ្តាញសង្គមហ្វេសប៊ុក ធ្វីតធ័រ និង Instagram។

# # #